**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Oct-2012, 14:45
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកការបំភ្លឺពី កសចស ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ កសចស ឲ្យផ្តល់ភស្តុតាងទាក់ទងនឹងការធ្វើបទសម្ភាសន៍នេះ"**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | **ក្រុមមេធាវីការពារក្តី:** |
| | | លោក សុន អរុណ |
| | **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក Michiel PESTMAN |
| | ពេជ អង្គ | លោក Victor KOPPE |

Elisabeth SIMONNEAU FORT

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន
Anta GUISSE
Arthur VERCKEN
Jacques VERGES

## I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាបានទទួលការជូនដំណឹងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ អំពីការដាក់ឯកសារមួយ (“សំណើ”) ដោយមេធាវីការពារក្តី អៀង សារី ដែលស្នើអង្គជំនុំជម្រះសាលាដំបូង: (១) ស្វែងរកការបញ្ជាក់ពី កសចស ប្រាំចំណុចនៃព័ត៌មានទាក់ទងនឹងការស្តាប់ចម្លើយធ្វើឡើងនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ជាមួយ នង សុផង់; (២) ដាក់កំណត់ហេតុដែលមាន ស្តីពីការស្តាប់ចម្លើយសាក្សីដូចបានពោលខាងលើនេះទៅក្នុងសំណុំរឿង និង(៣) “កោះហៅអ្នកស៊ើបអង្កេតមកផ្តល់ភ័ស្តុតាងទាក់ទងនឹងកាលៈទេសៈនៃការស្តាប់ចម្លើយសាក្សីនៅថ្ងៃទី១៧ និងទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ របស់អ្នកស៊ើបអង្កេតទាំងនោះជាមួយ នង សុផង់”[1](“សំណើ”)។

២- សហព្រះរាជអាជ្ញាសន្និដ្ឋានថា មេធាវីការពារក្តីមិនបានបង្ហាញអត្តសញ្ញាណពីកំហុសឆ្គងណាមួយដើម្បីជាយុត្តិកម្មសម្រាប់ដំណោះស្រាយតាមប្រភេទណាមួយឡើយ អាស្រ័យហេតុនេះ សំអាងហេតុនៃសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី គឺមានកំហុសឆ្គង។ សហព្រះរាជអាជ្ញាបានឆ្លើយតបពីមុនរួចហើយទៅសំណើស្រដៀងគ្នានេះ ទាក់ទងនឹង នង សុផង់ ដែលបានធ្វើឡើងដោយមេធាវីការពារក្តី ខៀវ សំផន[2]។ សំណើនោះបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង “សួរទៅ កសចស ឱ្យបញ្ជាក់អំពីការស្តាប់ចម្លើយសាក្សី នង សុផង់[3]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងគួរបដិសេធចោលសំណើនេះ ដោយសារសំណើនេះខកខានមិនបានបង្ហាញឱ្យឃើញនូវកំហុសឆ្គងណា

---

[1] **E234** សំណើរបស់ អៀង សារី ស្នើសុំឱ្យអង្គជំនុំជម្រះស្វែងរកការបញ្ជាក់ពី កសចស ទាក់ទងនឹងការសួរសំណួរ នង សុផង់ កាលពីថ្ងៃទី១៧ ខែកុម្ភ ឆ្នាំ២០០៩ និងសុំឱ្យធ្វើការកោះហៅអ្នកស៊ើបអង្កេតរបស់ កសចស ដើម្បីផ្តល់សក្ខីកម្មទាក់ទងនឹងកិច្ចសម្ភាសន៍នោះ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២ (ចាប់ពីពេលនេះទៅហៅថា សំណើ) គ្រប់ទំព័រ១៥ និងការជូនដំណឹងកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២។

[2] **E224/2** មតិគាំទ្រសំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្តិភាពឯកសារសម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨, ១០ កញ្ញា ឆ្នាំ២០១២។ **E224/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន គាំទ្រសំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្តិភាពខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨”, ១៨ កញ្ញា ២០១២។

[3] **E224/2** មតិគាំទ្រសំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្តិភាពឯកសារសម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ តុលា ឆ្នាំ២០០៨, ១០ កញ្ញា ឆ្នាំ២០១២, កថាខណ្ឌ៦។

មួយ ដើម្បីយុត្តិកម្មដំណោះស្រាយដែលបានស្នើសុំ[4]។ សំណើសុំក្លាមនេះគ្មានសំអាងដូចគ្នាដែរ និងត្រូវបដិសេធចោល។

៣- លើសពីនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា មានការបញ្ជាក់ជាច្រើនលើកច្រើនសារថា សំណើសុំមិនបានធ្វើឡើងក្នុងបំណងល្អទេ។ ខណៈដែលនេះគឺជាទឡ្ហីករណ៍ឯករាជ្យដែលត្រូវធ្វើសំអាង ដើម្បីបដិសេធចោលលើសំណើនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នឹងមានការពេញចិត្តជាខ្លាំងបើសិនអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចដាច់ខាតមួយលើការទាមទារ ទាក់ទងនឹងដំណាក់កាលនៃកិច្ចស៊ើបសួរក្នុងសំណុំរឿងលេខ០០២ ដែលក្រុមមេធាវីការពារក្តីបានលើកឡើងច្រំដែលៗនាពេលថ្មីៗនេះ

៤- សហព្រះរាជអាជ្ញាជំទាស់ទៅនឹងទម្រង់ទាំងអស់នៃសំណើសុំដំណោះស្រាយ របស់មេធាវីការពារក្តី ប៉ុន្តែមិនជំទាស់សំណើសុំឲ្យអង្គជំនុំជម្រះ ធ្វើការសាកសួរអំពីអត្ថិភាពនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី នង សុផង់ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទេ ហើយសូមឲ្យដាក់ក្នុងសំណុំរឿងនូវកំណត់ហេតុណាមួយបែបនេះប្រសិនបើមាន។ នៅពេលមិនមានភ័ស្តុតាងសោះ សក្ខីកម្មរបស់ នង សុផង់ មិនមានតម្លៃសមស្រប ហើយថាភ័ស្តុតាងផ្ទាល់មាត់របស់សាក្សីរូបនេះបានគាំទ្រដល់ភាពត្រឹមត្រូវ និងភាពជឿជាក់បានកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ពីមុនៗមក។ ប្រសិនបើការថតសម្លេងនៃកំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធជាមួយនឹងសាក្សីរូបនេះមានអត្ថិភាព នោះការដាក់កំណត់ហេតុនោះចូលក្នុងសំណុំរឿងជាការសមស្រប។

## II. **អំណះអំណាង**

### ក. មេធាវីការពារក្តីខកខានមិនបានបង្ហាញអំពីមូលដ្ឋានសម្រាប់ការទាមទាររបស់ខ្លួន ទាក់ទងនឹង នង សុផង់

[4] **E224/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន គាំទ្រសំណើរបស់ អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨", ១៨ កញ្ញា ២០១២, កថាខណ្ឌ២០។

៥- សំណើនេះខកខានមិនបានបង្ហាញឱ្យឃើញពីកំហុសឆ្គងណាមួយ ដើម្បីយុត្តិកម្មលើដំណោះស្រាយដែលបានស្នើសុំ ទាក់ទងនឹង នង សុផង់។ ដូចសហព្រះរាជអាជ្ញាបានពន្យល់ជាប់លាប់រួចហើយទាក់ទងនឹងការទាមទារស្រដៀងគ្នានេះដែរសំដៅលើសាក្សីដទៃទៀត[5] ហើយទាក់ទងទៅនឹង នង សុផង់[6]: (១) វិការៈផ្នែកនីតិវិធីណាមួយដែលបានកើតឡើងនៅដំណាក់កាលនៃកិច្ចស៊ើបសួរ ត្រូវបានដំណោះស្រាយ; (២) ការបង្ហាញខ្លួនរបស់ នង សុផង់ នៅក្នុងតុលាការ ដើម្បីផ្តល់សក្ខីកម្មដែលនៅក្នុងអម្លុងពេលផ្តល់សក្ខីកម្មនោះ មេធាវីការពារក្តីអាច និងបានសួរ សាកល្បងលើភ័ស្តុតាងរបស់គាត់ ដើម្បីការពារសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌របស់ អៀង សារី និង(៣) កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីរបស់ នង សុផង់ ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវទៅនឹងបទសម្ភាសន៍របស់គាត់ និងអនុវត្តទៅតាមវិធានរបស់ អ.វ.ត.ក។

### *i. វិការៈផ្នែកនីតិវិធីដូចបានចោទប្រកាន់នៅក្នុងកិច្ចស៊ើបសួរ ត្រូវបានដំណោះស្រាយដោយដីកាដំណោះស្រាយ*

៦- សំណើនេះបានផ្អែកលើវិការៈផ្នែកនីតិវិធីដែលបានចោទប្រកាន់នៅក្នុងកិច្ចស៊ើបសួរ ជាពិសេសពីរបៀបនៃការស្តាប់ចម្លើយសាក្សី នង សុផង់ បានធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ កសចស។ ប៉ុន្តែដូចដែលអង្គជំនុំជម្រះបានសម្រេចកាលពីលើកមុនថា“វិធានផ្ទៃក្នុងមិនបានចែងអំពីការសួរដេញដោលដោយអង្គជំនុំជម្រះសាលាដំបូង អំពីភាពត្រឹមត្រូវនៃនីតិវិធីនៃការស៊ើបសួរ ក្រោយពេលទទួលបានសំណុំរឿងនេះទេ”[7]។

[5] *សូមមើល* **E224/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងសុំការបញ្ជាក់ពី កសចស អំពីអត្ថិភាពនៃកំណត់ត្រា និងការថតសម្លេងនានាទាក់ទងនឹងការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨”, ៧ កញ្ញា ២០១២។ **E221/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឱ្យស្តាប់ការបង្ហាញភ័ស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរ ធ្វើឡើងដោយ កសចស, ៤ កញ្ញា ២០១២។

[6] **E224/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន គាំទ្រសំណើរបស់ អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨”, ១៨ កញ្ញា ២០១២។

[7] **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ៩ កញ្ញា ២០១១, កថាខណ្ឌ១៧ (ចាប់ពីនេះតទៅហៅថា “សេចក្តីសម្រេចអំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ”)។

៧- អនុលោមតាមវិធានទាំងនេះ ការស្នើសុំទាក់ទងនឹងវិការៈផ្នែកនីតិវិធីអាចដាក់បានតែក្នុងដំណាក់កាលនៅមុនសវនាការប៉ុណ្ណោះ ហើយអង្គជំនុំជម្រះនេះបានរកឃើញថា "ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ គឺមានការការពារតាមនីតិវិធីច្បាប់គ្រប់គ្រាន់ដល់ជនជាប់ចោទ រួមទាំងឱកាសក្នុងការដោះស្រាយជាមួយសហចៅក្រមស៊ើបអង្កេតលើបញ្ហាផ្សេងៗ និងការធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ លើសេចក្តីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត ក្នុងករណីចាំបាច់"[8]។

៨- ការការពារទាំងនេះ រួមបញ្ចូលសំណើសុំបំពេញកិច្ចស៊ើបសួរ ធ្វើឡើងស្របតាមវិធាន៥៥(១០)។ យ៉ាងណាមិញ ពេលវេលាបានកន្លងផុតទៅយ៉ាងចំណែក ដែលមេធាវីការពារក្តីពឹងផ្អែកទៅលើ"សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបីរបស់ អៀង សារី"[9]។ សំណើមួយដែលមិនមានកន្លែងណាមួយលើកឡើងពីភាពមិនប្រក្រតីជាក់លាក់ដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងបទសម្ភាសន៍សាក្សីឡើយ ហើយថាសំណើសុំណាមួយដែលសម្រេចដោយអង្គបុរេជំនុំជម្រះទោះបីក្នុងករណីណាក៏ដោយ "មិនប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទដែលត្រូវតែធ្វើទេ ស្របតាមច្បាប់ជាធរមានរបស់ អ.វ.ត.ក ឬវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក"[10]ឡើយ។ ជាការភ្ញាក់ផ្អើលផងដែរថាមេធាវីការពារក្តីមិនបានយោងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅកន្លែងណាមួយទេក្នុងសំណើសុំរបស់ខ្លួន។

៩- ទោះជាយ៉ាងណាក្តី កសចស បានធ្វើការឆ្លើយតបទៅនឹង "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីបី"របស់ កសចស[11][12]។ ជាបន្ថែមពីលើការលើកឡើងអះអាងរបស់ក្រុមមេធាវីការពារក្តីដែលខុសអំពីថា កសចស បានរំលោភទៅលើវិធាន២៥នៃវិធានផ្ទៃក្នុង ដូចដែលបានរៀបរាប់យ៉ាងពេញលេញជាងនេះនៅក្នុងអនុផ្នែកII(ក)(iii)ខាងក្រោមនេះ ក្រុមមេធាវីការពារក្តីខកខានមិនបានបង្ហាញឱ្យឃើញអំពីថាតើព័ត៌មានទូទៅដែលពួកខ្លួនបានស្នើសុំនោះគាំទ្របែបដូចម្តេចខ្លះ ដល់ការលើកឡើងអះអាងរបស់ពួកខ្លួនទាក់ទងទៅនឹង នង សុផង់ នោះទេ។ ក្រុមមេធាវីការពារក្តីបានអះអាងយ៉ាងមឹងម៉ាត់ថា

---

[8] **E116** សេចក្តីសម្រេចអំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ១៨។

[9] **D171** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីបី របស់ អៀង សារី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩។

[10] **D171/4/5** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីបីរបស់ អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរ, ២២ ធ្នូ ២០០៩, កថាខណ្ឌ៩។

[11]ឯកសារលេខ **D171/5** អនុស្សរណៈ : " សំណើរបស់លោក "ដែលសុំឱ្យបំពេញកិច្ចស៊ើបសួរ" ស្តីពី, *នៅក្នុងចំណោមអ្វីៗដទៃជាច្រើនទៀត*, យុទ្ធសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកិច្ចស៊ើបសួរ, ចុះថ្ងៃទី២១ ឧសភា ២០០៩។

[12] ឯកសារលេខ **E234** សំណើ, ត្រង់កថាខណ្ឌទី១៩។

"បើសិនជា កសចស ផ្តល់ព័ត៌មានដែលបានស្វែងរកសុំនោះ ក្រុមមេធាវីការពារក្តី នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរនៃដំណើរការនីតិវិធី មុខជានឹងមានការត្រៀមលក្ខណៈដើម្បីបង្ហាញជូនថា កិច្ចស៊ើបសួរត្រូវបាន និងកំពុងអនុវត្តនៅក្នុងលក្ខណៈមួយដែលមិនច្បាស់លាស់ និងមិនទៅតាមតាមបទដ្ឋាន"[13] ហើយ ក្រុមមេធាវីការពារក្តីនៅមិនទាន់បានទទួលស្គាល់នៅឡើយថា មូលដ្ឋាននៃសំណើសុំរបស់ពួកគេដែលពាក់ព័ន្ធតែទៅនឹងការធ្វើសម្ភាសន៍នងសុផង់តែប៉ុណ្ណោះនោះ គឺខ្សែអាត់ថតសម្លេងនៃការធ្វើសម្ភាសន៍នោះដែលពួកខ្លួនអាចមានសិទ្ធិចូលទៅពិនិត្យមើលបាន នៅក្នុងអម្លុងពេលនៃដំណាក់កាលនៃកិច្ចស៊ើបសួរ[14]។ អាស្រ័យហេតុនេះ មិនមានភាពច្បាស់លាស់ទេថា តើព័ត៌មាន*បន្ថែមពីលើនេះទៀត*នឹងមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះមួយចំនួនទៅលើសំណើចំពោះមុខនេះ នៅពេលដែលមេធាវីការពារក្តីខកខានក្នុងការពិនិត្យឡើងវិញទៅលើព័ត៌មានដែលមានស្រាប់រួចហើយសំរាប់ពួកគេនោះ។ ក្រុមមេធាវីការពារក្តីបានខិតខំព្យាយាមលាក់បំបាំងនូវការខកខានរបស់ពួកខ្លួននៅក្នុងការអនុវត្ត ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ និងក្នុងការធ្វើសំណើពាក់ព័ន្ធមកឲ្យបានទាន់ពេលវេលានៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរដែលនៅពីក្រោយការសន្មតអំពីការខកខានរបស់ កសចស ក្នុងការមិនបានឆ្លើយតបទៅនឹងសំណើដែលមានលក្ខណៈទូលំទូលាយដែលសុំឲ្យផ្តល់ព័ត៌មានស្តីពីប្រព័ន្ធ និងនីតិវិធីផ្សេងៗដែលសំណើនោះ កសចស មិនត្រូវបានតម្រូវឲ្យបំពេញតាមជាដំបូងគេនោះឡើយ។

១០- បន្ថែមលើសំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន៥៥(១០) ក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ មេធាវីការពារក៏មានសិទ្ធិស្របតាមវិធាន៧៦ ធ្វើសំណើមោឃភាពកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ ឬកិច្ចស៊ើបសួរផ្សេងទៀត និងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចណាមួយ។ តាមពិត លោកប្រធានក៏បានលើកចំណុចនេះ ដល់មេធាវីការពារក្តីក្នុងអម្លុងនៃការសួរដេញដោល នង សុផង់ ដែរ[15]។ អំណះអំណាងនេះ ដែលដូចជាកម្រិតធនធាន និងកម្រិតជម្រើសក្នុងការផ្តោតទៅលើទិដ្ឋភាពខាងផ្នែកច្បាប់ និងផ្នែកបច្ចេកទេសនៃការស៊ើបសួររបស់មេធាវីការពារក្តី គឺ ទាំងស្រុង មិនអាចឲ្យជឿជាក់បានឡើយ - យ៉ាងហោចណាស់ ក៏មេធាវីការពារក្តីត្រូវមានកាតព្វកិច្ចធ្វើការត្រួតពិនិត្យឡើងវិញ

---

[13]ឯកសារលេខ **E234** សំណើ, ត្រង់កថាខណ្ឌទី១ (ក)។

[14] *សូមអានផងដែរឯកសារលេខ* **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី ដែលស្នើសុំឲ្យបើកសវនាការស្តីពីការដឹកនាំកិច្ចស៊ើបសួរ, ចុះថ្ងៃទី ៨ ខែមេសា ២០១១, ទំព័រ២ (" ភាគីនានាអាច ដាក់ជូននូវពាក្យសុំដោយមានការបញ្ជាក់ពីមូលហេតុ អំពីផ្នែកណាមួយនៃដំណើរការនីតិវិធីដែលពួកគេបានចាត់ទុកថា ត្រូវធ្វើមោឃៈភាពនៅក្នុងអម្លុងនៃកិច្ចស៊ើបសួរនោះផ្ទាល់តែម្តង និង ...សេចក្តីសម្រេចណាមួយទាក់ទងទៅនឹងពាក្យសុំទាំងនេះត្រូវបានបើកឲ្យប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះបាន ដោយអនុលោមតាមវិធានផ្ទៃក្នុង")។

[15] **E1/123.1** ប្រតិចារឹក, ៦ កញ្ញា ២០១២, ទំព័រ៣៤ ("ក្នុងដំណាក់កាលស៊ើបសួរ បើសិនភាគីណាមួយស្នើសុំមោឃភាព ភាគីនោះត្រូវធ្វើដូច្នេះបានតាមរយៈសហចៅក្រមស៊ើបអង្កេត តាមការដាក់បណ្តឹងឧទ្ធរណ៍សុំមោឃភាពទៅអង្គបុរេជំនុំជម្រះ")។

ដោយប្រុងប្រយ័ត្នទៅលើប្រភេទនានានៃភ័ស្តុតាងទាំងឡាយណា ដែលមានការទាក់ទងយ៉ាងជាក់លាក់ទៅនឹងកូនក្តីរបស់ខ្លួន និង ដែលត្រូវបាន និងកំពុងដាក់នៅក្នុងសំណុំរឿង។ ភ័ស្តុតាងប្រភេទនេះ (ដូចជាកំណត់ហេតុស្តាប់ចម្លើយរបស់ នង សុផង់ ជាដើម) បង្កើតបានជាការប្រមូលចងក្រងនូវកំណត់ហេតុនានាដែលមានកម្រិត ព្រមទាំងសម្ភារៈសោតទស្សន៍ផង បានច្រើនជាងការប្រមូលចងក្រងដែលមាននៅក្នុងសំណុំរឿងទាំងមូលដែលមេធាវីការពារក្តីធ្លាប់ បានយោងដល់នោះទៅទៀត

១១- នៅពេលមានការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ភាគីទាំងអស់នៅមានឱកាសបន្ថែមទៀតក្នុងការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ហើយការជំទាស់ណាមួយលើសំណើនោះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍[16]។ មេធាវីការពារក្តីមិនបានស្នើសុំបំពេញកិច្ចស៊ើបសួរណាមួយបន្ថែមឡើយ នៅក្នុងចំណុចនេះទាក់ទងនឹង នង សុផង់។

១២- បន្ទាប់ពីមានឱកាសទាំងអស់នេះដើម្បីកែតម្រូវក្តីកង្វល់ណាមួយដែលគេអាចដឹងបាន បានកន្លងផុតទៅដោយមេធាវីការពារក្តីមិនបានប្រើប្រាស់ ដីកាដំណោះស្រាយក៏បានចេញ។ វិធាន៧៦(៧)ចែងថា: “លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវតែកែតម្រូវកំហុសនីតិវិធីក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”[17]។ ហេតុដូចនេះ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងច្បាស់ថាការតវ៉ាខាងនីតិវិធីលើកិច្ចស៊ើបសួរ ត្រូវបានកំហិតត្រឹមដំណាក់កាលមុខសវនាការប៉ុណ្ណោះ។ វាជារឿងចំឡែក និងជាការលាតត្រដាងឲ្យដឹងពីភាពមិនស្មោះត្រង់ប៉ុន្មាននៃសំណើនេះ ដែលថាមេធាវីការពារក្តីសូម្បីតែវិធាន៧៦(៧) ក៏មិនបានលើក។

១៣- កិច្ចដែលបានស្នើឡើងដោយមេធាវីការពារក្តីស្វែងរកការស្តាប់ចម្លើយរបស់អ្នកស៊ើបអង្កេត និងការពន្យល់ផ្សេងៗពី កសចស ក្នុងពេលដែលគ្មានភ័ស្តុតាងអំពីភាពមិនប្រក្រតីដែលជាបញ្ហាជាក់លាក់អាចបំពានទៅលើការកំណត់ដែលបានចែងទាំងនៅក្នុងវិធានផ្ទៃក្នុង និងទាំងនៅក្នុងរចនាសម្ព័ន្ធទូទៅរបស់ អ.វ.ត.ក រវាងដំណាក់កាលកិច្ចស៊ើបសួរ និងសវនាការ។ អង្គជំនុំជម្រះសាលាដំបូងមិនមែនជា

---

[16] វិធាន៦៦ នៃវិធានផ្ទៃក្នុង។

[17] *សូមមើលផងដែរ* **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការជម្រះដោយលើការបំពេញកិច្ចស៊ើបសួរ, ៨ មេសា ២០១១, ទំព័រ២។

"ស្ថាប័នឧទ្ធរណ៍ ឬស្ថាប័នពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះឡើយ"[18]។ ទន្ទឹមនេះ "បញ្ហាទូទៅ ការជំទាស់ផ្សេងៗទាក់ទងនឹងដំណាក់កាលនីតិវិធី ឬសេចក្តីសម្រេចដែលបានធ្វើឡើងដោយ សចស និងអង្គបុរេជំនុំជម្រះ នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ ត្រូវតែលើកឡើងនៅចំពោះមុខតុលាការមានសមត្ថកិច្ច មុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ"[19]។

១៤- អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការលើកលែងតាមវិធាន៧៦(៧) អាចនឹងធ្វើទៅបាន "បើភាគីអាចបង្ហាញថា ខ្លួនមិនមានឱកាសរកឱ្យឃើញនូវការបំប្លែងដែលត្រូវបានចោទប្រកាន់ នៅមុនពេលបើកសវនាការ ឬក្នុងករណីមានភាពចាំបាច់ដើម្បីការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី"[20]។ គ្មានការលើកលែងណាមួយក្នុងចំណោមករណីលើកលែងទាំងនោះ អាចអនុវត្តបានទីនៅទីនេះ។ មេធាវីការពារក្តីមានឱកាសច្រើន ដើម្បីរកឱ្យឃើញបញ្ហាដែលបានចោទប្រកាន់នៅក្នុងសំណើរបស់ខ្លួន គេបានអះអាងថា គេទើបបានដឹងពេលសួរសំណួរទៅកាន់ នួន ជា ក្នុងខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយរបស់គាត់[21]។ ដូចអង្គជំនុំជម្រះបានកត់សម្គាល់ពីមុនថា:

> *ទាំងក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងការថតសម្លេងនៃការស្តាប់ចម្លើយសាក្សី... ត្រូវបានដាក់ចូលក្នុងសំណុំរឿងជាបន្តបន្ទាប់ ក្នុងអម្លុងពេលបំពេញកិច្ចស៊ើបសួរ ហើយដូច្នេះភាគីមានលទ្ធភាពពិនិត្យមើលឯកសារទាំងនោះបាន (ទាំងអ្នកចេះភាសាខ្មែរ ភាសាអង់គ្លេស និង/ឬភាសាបារាំង) អស់រយៈពេលច្រើនឆ្នាំកន្លងមកនេះ"[22]។*

១៥- ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើដែលដាក់ដោយមេធាវីការពារក្តី នួន ជា អនុលោមវិធាន ៣៥ ដោយមានមូលដ្ឋានលើភាពមិនស៊ីសង្វាក់គ្នាដែលបានចោទប្រកាន់ រវាងការថតសម្លេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស ដោយបានរកឃើញថា "នៅក្នុងអំឡុងពេលដំណាក់កាលស៊ើបសួរ ភាគីទាំងអស់មានសិទ្ធិពិនិត្យសំណុំរឿង

---

[18] **E116** សេចក្តីសម្រេចអំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ១៨។

[19] **E116** សេចក្តីសម្រេចអំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ១៥។

[20] **E142/3** សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ នួន ជា អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស, ១៣ មីនា ២០១២, កថាខណ្ឌ៧ (ចាប់ពីនេះតទៅហៅថា "សេចក្តីសម្រេចអំពីការស្តាប់ចម្លើយសាក្សី")។

[21] **E234** សំណើ, កថាខណ្ឌ១(ក)។

[22] **E142/3** សេចក្តីសម្រេចអំពីការស្តាប់ចម្លើយសាក្សី, កថាខណ្ឌ៦, ៨។

រួមទាំងខ្សែអាត់ថតសម្លេង” ហើយថាមេធាវីការពារក្តីខកខានមិនបានបង្ហាញថា វាមិនមានលទ្ធភាពអាចនឹងធ្វើការវាយតម្លៃអំពីអត្ថិភាពនៃភាពមិនប្រក្រតី នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនានា “នៅមុនពេលបើកសវនាការ”[23]។ ស្រដៀងគ្នាដែរ នៅទីនេះ មេធាវីការពារក្តីអាចពិនិត្យឡើងវិញនូវការថតសម្លេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ នួន ជា។ ដូច្នេះ ពុំមានសេចក្តីដោះសាតាមផ្លូវច្បាប់ណាមួយ សម្រាប់ការខកខានមិនបានរកឃើញ និងមិនបានលើកឡើងពីការបារម្ភដែលបានសន្មតថា មេធាវីការពារក្តីនៅពេលនេះបានលើកឡើង នៅមុនពេលបើកសវនាការឡើយ។

១៦- ថ្មីៗនេះ ចៅក្រម Cartwright បានបញ្ជាក់ឡើងវិញជាថ្មីនូវគោលការណ៍ទាំងនេះ ជូនដល់ភាគីនានានៅក្នុងតុលាការថា៖

> *ហេតុដូច្នេះវិធានទូទៅនោះគឺថា មានសច្ចធារណ៍គតិយុត្តិអំពីសុចរិតភាពនៃការស៊ើបអង្កេត និងថារាល់ការព្រួយបារម្ភពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឬកម្មវត្ថុណាមួយដែលកើតមានឡើងក្នុងអំឡុងពេលស៊ើបអង្កេតនេះ ត្រូវតែលើកឡើងក្នុងអំឡុងពេលស៊ើបអង្កេតនោះតែម្តង។ ហើយឥឡូវនេះគឺនៅក្នុងពេលសវនាការនេះ ... ការស៊ើបអង្កេតត្រូវបានចាត់ទុកថាជាចំណុចចាប់ផ្តើម ហើយអាចជំទាស់តវ៉ាតែនៅក្នុងករណីលើកលែងមួយចំនួនតែប៉ុណ្ណោះ។ រាល់ការជំទាស់តវ៉ាទាំងនោះ មិនមែនតែពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេសទេ ក៏ប៉ុន្តែវាត្រូវពាក់ព័ន្ធទៅនឹងខ្លឹមសារផងដែរ។ ហើយការលើកឡើងចំពោះការលើកលែងនេះ គឺថា[ភាគី]ត្រូវតែធ្វើឲ្យត្រូវទៅតាមអង្គជំនុំជម្រះថាភាគីមានមូលហេតុគ្រប់គ្រាន់ដែលពាក់ព័ន្ធទៅនឹងការគួរឲ្យជឿជាក់បាន នៅត្រង់ផ្នែកណាមួយនៃការស៊ើបអង្កេត។ ដូច្នេះ ភាគីមិនអាចយក ពាក្យពេជន៍នៃច្បាប់ខំមិនឡ ដូចជាស្ទូច...ឲ្យបានឆាប់របហ័ស។*
>
> *...ភាគីចាំបាច់ធ្វើទៅតាមអង្គជំនុំជម្រះថាមានមូលដ្ឋានសម្អាងហេតុគ្រប់គ្រាន់ សម្រាប់ត្រលប់ទៅរកការស៊ើបអង្កេតឡើងវិញ និងធ្វើការស៊ើបអង្កេត*[24] ។

[23] **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី៨។

[24] **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២, ទំព័រទី៤៣ ។ សូមអានផងដែរ *ដដែលដូចមុន* ត្រង់ទំព័រទី ៣៦-៣៧ (កន្លែងដែលចៅក្រម Lavergne បានកត់សម្គាល់ថា “អង្គហេតុជាក់ស្តែបំផុតមួយចំនួន” ដោយរួមទាំងថា “ការស៊ើបអង្កេតរបស់តុលាការ

១៧- ពិតមែនហើយ ដូចដែលចៅក្រម Cartwright បានធ្វើការសង្កេតដូច្នេះថា ការប្រព្រឹត្តិរបស់ កសចស គឺសមនឹងបានទទួលនូវការសន្និដ្ឋានជាមុនអំពីភាពមិនប្រក្រតី ដែលមិនអាចត្រូវបានបដិសេធដោយញត្តិ ដែលត្រូវបាន "ពិចារណាថាជាការនិយាយស្មានៗ ឬមិនបានបង្ហាញភ័ស្តុតាង" ដូចក្នុងសំណើភ្លាមនេះទេ[25]។

*ii. សក្ខីកម្មរបស់សាក្សីរូបនេះបានដោះស្រាយពេលលេញនូវបញ្ហាអំពីនៃកាលៈទេសៈមួយចំនួននៃកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ជាមួយនឹង កសចស និងការពារបាននូវសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវរបស់ជនជាប់ចោទ*

១៨- លើសពីនេះ ករណីលើកលែងមួយនៅក្នុងវិធាន៧៦.៧ នៃវិធានផ្ទៃក្នុង នៅទីនេះ គឺមិនចាំបាច់នៅក្នុងការធានាអំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះទេ។ សូម្បីតែមានកំហុសនីតិវិធីនៅក្នុងរបៀបដែលគេបានស្តាប់ចម្លើយ នង សុផង់ ក៏ដោយ ក៏សាក្សីរូបនេះបានផ្តល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះរួចហើយ ហើយមេធាវីការពារក្តីពិតជាមានឱកាសធ្វើការតាំងសំណួរដេញដោលទាំងខ្លឹមសារនៃសក្ខីកម្មរបស់គាត់ និងទាំងនីតិវិធី បន្ទាប់ពីការស្តាប់ចម្លើយរបស់គាត់ដោយ កសចស[26] ហើយមេធាវីការពារក្តីដទៃទៀត បានធ្វើដូច្នេះដែរ[27]។ នេះគឺជានីតិវិធីដែលបានអនុញ្ញាតឲ្យមេធាវីការពារក្តី "សាកល្បងសុចរិតភាពនៃសក្ខីកម្មរបស់សាក្សី"[28]។ នៅក្នុងការច្រានចោលសំណើដែលដាក់ដោយមេធាវីការពារក្តី នួន ជា អនុលោមវិធាន ៣៥ ដោយផ្អែកទៅលើភាពមិនស៊ីសង្វាក់គ្នាដែលបានចោទប្រកាន់ រវាងការថតសម្លេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មេធាវីការពារក្តី "ក្នុងកាលៈទេសៈណាក៏ដោយ នឹងមានការការពារ

---

ដែលបានធ្វើឡើងមុនការជំនុំជម្រះ គឺថាមានរយៈពេលរាប់ឆ្នាំមកហើយ។ ហើយនៅអំឡុងពេលនៃកិច្ចស៊ើបសួរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ក្រុមមេធាវីការពារក្តីក៏អាចចូលមើលសំណុំរឿងនេះបានដែរ។ ហើយជនជាប់ចោទក៏អាច ពិនិត្យមើលបាន។ … យើងមិនពិភាក្សាអំពីស៊ើបអង្កេតនៅពេលនេះទេ… នៅទីនេះគឺយើងសិក្សា និងពិនិត្យលើបញ្ហាដែលសំខាន់។ បញ្ហាដែលទាក់ទងនឹងការស៊ើបអង្កេតរបស់តុលាការ មិនត្រូវលើកយកមកធ្វើជាប្រធានបទដដែល ឬច្រំដែលនោះទេ។

[25] **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី១០។

[26] **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២, ទំព័រទី ២៨-១០៨។

[27] **E1/122.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៥ កញ្ញា ២០១២, ត្រង់ទំព័រទី ៣៨-១០២។ **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២, ទំព័រទី ៥-២៨។

[28] **E234** សំណើ, ត្រង់ទំព័រទី១។

បន្ថែមទៀតដែលផ្តល់លទ្ធភាពឲ្យសួរសំណួរដល់សាក្សីនៅពេលសវនាការស្តីពីភាពមិនស៊ីសង្វាក់ដែលបានចោទប្រកាន់ទាំងនេះ ក្នុងករណីដែលភាពមិនស៊ីសង្វាក់ដែលបានចោទប្រកាន់ទាំងនេះ បង្ហាញមានភាពពាក់ព័ន្ធក្នុងការវាយតម្លៃភ័ស្តុតាងភរនី ឬចាំបាច់ការពារភាពត្រឹមត្រូវនៃនីតិវិធីសវនាការ"[29]។ សិទ្ធិទទួលបានសវនាការត្រឹមត្រូវរបស់ត្រូវបានការពារគ្រប់គ្រាន់រួចជាស្រេច ទាក់ទងទៅនឹងសក្ខីកម្មរបស់ សាក្សីរូបនេះ។

១៩- ដើម្បីឲ្យបានច្បាស់ សហព្រះរាជអាជ្ញាគាំទ្រដល់សិទ្ធិរបស់ក្រុមមេធាវីការពារក្តីទាំងឡាយ ដែលបានដាក់សំណើដែលមានហេតុផលទាក់ទងទៅនឹងសាក្សីនានា ពាក់ព័ន្ធទៅនឹងនីតិវិធីនៃការស្តាប់ចម្លើយសាក្សីរូបនេះ។ ដូចដែលសហព្រះរាជអាជ្ញាបានថ្លែងនៅក្នុងតុលាការដូច្នោះដែរថា "យើងអាចយល់ស្របជាមួយមេធាវីការពារក្តីថា ក្នុងករណីមានភាពមិនស៊ីសង្វាក់គ្នាច្រើនបានកើតឡើង ក្នុងករណីមានបញ្ហាធម្មានុរូបទាក់ទងនឹងសុចរិតភាពរបស់សាក្សី...នោះសិទ្ធិមួយចំនួនគួរទុកជូនមេធាវី ដើម្បីស្រាវជ្រាវកំណត់ហេតុស្តាប់ចម្លើយពីមុន និងប្រតិចារឹកពីមុន ជានិច្ចកាល យើងនឹងគាំទ្រសិទ្ធិមេធាវីការពារក្តីក្នុងការសាកល្បងភ័ស្តុតាង ប៉ុន្តែនេះជាកម្រិតនៃបញ្ហា និងក្នុងករណីនេះ បញ្ហាប្រាដកជាបានឃ្លាតឆ្ងាយពីអ្វីដែលមានធម្មានុរូប "[30]។

២០- ជាចាំបាច់ណាស់ក្នុងការកត់សម្គាល់ថា ទាក់ទងទៅនឹង នង សុផង់ មេធាវីការពារក្តីពិតជាមានឱកាសសួរសំណួរនានាទាក់ទងនឹងដំណើរការនៃកិច្ចស៊ើបសួរនោះ ទោះបីជាអ្នកអានម្នាក់ដែលផ្អែកទៅលើអ្វី ដែលមេធាវីការពារក្តីសង្ខេបថាជា "ផ្នែកពាក់ព័ន្ធ" នៃប្រតិចារឹក ចាប់ពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១២ គួរត្រូវបានអត់អោន ដោយសារជឿថា កំណត់ហេតុនេះមិនបាននិយាយទេ នៅពេលដែលការផ្លាស់ប្តូរទាំងនោះ មិនត្រូវបានគេលើកយកមកអះអាង និងមិនត្រូវបានគេដកសម្រង់សម្តីនៅក្នុងនោះ។

២១- ពិតមែនហើយ នៅលើទំព័របន្ទាប់ពីកន្លែងដែលសេចក្តីសន្និដ្ឋានលើ "ផ្នែកពាក់ព័ន្ធ" របស់មេធាវីការពារក្តីបានបញ្ចប់នោះ[31] ប្រតិចារឹកបានបង្ហាញថា មេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី គឺ

---

[29] **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី១៤។ *សូមអានផងដែរ* **E116** សេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌទី១៩។

[30] **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២, ទំព័រទី ៤១។

[31] **E234** សំណើ, ត្រង់កថាខណ្ឌទី ២.៤។

Michael Karnavas បានសួរសំណួរផ្សេងៗជាច្រើនដល់ នង សុផង់ ពាក់ព័ន្ធនឹងកិច្ចសន្ទនាដែលសាក្សីរូបនេះមានជាមួយនឹងពួកអ្នកស៊ើបអង្កេត នៅមុនពេលដែលការស្តាប់ចម្លើយត្រូវបានថតសម្លេង រួមមាន "នៅថ្ងៃមុនពេលដែលលោកត្រូវបានគេសម្ភាសន៍នៅក្នុងខ្សែអាត់សម្លេងនេះ តើលោកមានបានជួបជាមួយអ្នកស៊ើបអង្កេតដែរ ឬទេ? ការពិត តើលោកមាននៅចាំបានទេថាតើលោកបានពិភាក្សាពីបញ្ហារបស់ ប៉ង់ មុនពេលដែលលោកត្រូវបានគេថតសម្លេងដែរ ឬទេ? នៅថ្ងៃដែលកិច្ចសម្ភាសន៍របស់លោកត្រូវបានគេថតជាខ្សែអាត់សម្លេង តើលោកមានត្រូវគេសាកសួរមុនពេលគេធ្វើសម្ភាសន៍ដែរ ឬទេ? ចុះចំណែកកិច្ចសន្ទនារបស់លោកនៅមុននេះមួយថ្ងៃ យ៉ាងហោចណាស់ តើលោកអាចប្រាប់យើងខ្ញុំថាតើវាមានរយៈពេលយូរប៉ុន្មាន តើមានការជជែកគ្នាលេងយូរប៉ុន្មានមុននោះមួយថ្ងៃ"ផង[32]។ នង សុផង់ បានឆ្លើយតបគ្រប់សំណួរទាំងអស់របស់លោក Karnavas ដែលបានបន្តជាប់មិនដាច់រហូតទាល់តែលោក Karnavas ខ្លួនឯងផ្ទាល់បានសម្តែងចេញនូវការពេញចិត្ត ហើយបានសម្រេច ថាគាត់ចង់លើកឡើងពីប្រធានបទមួយផ្សេងទៀត ដោយបានថ្លែងថា "សូមអរគុណច្រើនយើងគួរតែទៅមុខបន្តិចទៀត..."។ កំណត់ត្រាបានបង្ហាញយ៉ាងច្បាស់ពីរបៀបដែលមេធាវីការពារក្តីអាចមានលទ្ធភាពសួរដេញដោល លើភ័ស្តុតាងរបស់ នង សុផង់ និងភាពគួរឲ្យជឿបានរបស់គាត់ - រួមទាំង ការសួរសំនួរនានាដែល ទាក់ទងទៅនឹងការពិភាក្សារបស់គាត់ជាមួយនឹង កសចស ផង។ តាមអង្គហេតុពិត ជាងពីរ-បីថ្ងៃ នៃការសួរសំណួរស្តីពីបញ្ហាបច្ចេកទេសដ៏ជ្រាលជ្រៅកន្លងមកនេះ កំណត់ត្រាបានបង្ហាញពីរបៀបដែល សាក្សីរូបនេះបានផ្តល់នូវភ័ស្តុតាងដ៏ច្បាស់លាស់ និងប្រទាក់ក្រឡាគ្នា ដែលស៊ីគ្នាទាំងស្រុងទៅនឹងចម្លើយពីមុនៗរបស់គាត់។ មិនមានចំណែកតូចណាមួយនៃព័ត៌មានដែលគាំទ្រដល់អំណះអំណាង ដែលថាសាក្សីរូបនេះត្រូវបានបានទទួលឥទ្ធិពលមិនត្រឹមត្រូវពី កសចស នៅមុនពេលការផ្តល់ ចម្លើយរបស់គាត់នោះឡើយ។

២២- លើសពីនេះទៀត មេធាវីការពារក្តីនេះមិនមែនជាក្រុមមេធាវីការពារក្តីតែមួយទេ ឬជាលើកទីមួយទេដែលបានលើកសំណួរច្បាស់លាស់នេះ។ តាមពិតទៅ នៅថ្ងៃមួយ មុនពេលដែលលោក Karnavas បានតាំងសំណួររបស់គាត់ចំពោះ នង សុផង់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សីរបស់ កសចស លោក Arthur Vercken ដែលជាមេធាវីការពារក្តីអន្តរជាតិរបស់ ខៀវ សំផន ក៏បានសួរសាក្សីរូបនេះអំពីកំណត់ហេតុស្តាប់ចម្លើយនានាពីមុនផងដែរ ហើយបានធ្វើការសន្និដ្ឋានស្រដៀងគ្នានេះដែរអំពី

[32] **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២, ទំព័រទី ៤៥-៤៦។

សំណួរនោះថាជាឆន្ទៈផ្ទាល់របស់គាត់[33]។ មេធាវីការពារក្តី នួន ជា ក៏បានចូលរួមផងដែរទៅនឹងការតាំងសំណួរពាក់ព័ន្ធនឹងការប្រព្រឹត្តិ - ជាជាងខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយរបស់ កសចស ទោះបីជាមានបែបខុសគ្នាក៏ដោយ[34]។

២៣- គួរតែសង្កត់ធ្ងន់ផងដែរថា ឥឡូវនេះ នង សុផង់ បានផ្តល់សក្ខីកម្មពាក់ព័ន្ធនៅចំពោះមុខអង្គជំនុំជម្រះដែលជាសរុបមានចំនួនបីថ្ងៃកន្លះរួចមកហើយ[35] បញ្ហានៃការពិភាក្សារបស់គាត់ពីមុនៗមកជាមួយនឹង កសចស គឺមានផលវិបាកបន្តិចបន្តួច ឬគ្មានទេ។ ការផ្តល់សក្ខីកម្មរបស់គាត់ នៅក្នុងតុលាការ អស់រយៈពេលចំនួនបីថ្ងៃកន្លះ ជាភស្តុតាងចម្បង នៅចំពោះមុខអង្គជំនុំជម្រះ នាពេលនេះ។ មេធាវីការពារក្តីបានស្វែងរកនូវការអះអាងមួយ ដែលថាកំហុសនោះបានលេចចេញពីការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សី នង សុផង់ ដើម្បីរំលឹកការចងចាំរបស់គាត់នៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់[36]។ យ៉ាងណាក៏ដោយ ដូចដែលបានរៀបរាប់បន្ថែមទៀតនៅខាងក្រោមនេះ កំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះ គឺត្រូវគ្នាទៅនឹងវិធានផ្ទៃក្នុង ដូច្នេះ កំណត់ហេតុនេះមិនជាបញ្ហាត្រូវដោះស្រាយនោះទេ។ សំខាន់ជាងនេះ គ្រប់ពេល នង សុផង់ ត្រូវបាបង្ហាញ ដោយមានការឆ្លងកាត់ពីកំណត់ហេតុរបស់គាត់ ដែលគាត់មានឱកាស បញ្ជាក់ បដិសេធ និង/ឬ ផ្ទៀងផ្ទាត់ឲ្យបានច្បាស់លាស់ពីសច្ចសីលភាពនៃកំណត់ហេតុនោះ។ ជាថ្មីម្តងទៀត មេធាវីការពារក្តីក៏មានឱកាសផងដែរ នៅក្នុងការសួរសំណួរដល់ នង សុផង់ ក្នុងអង្គហេតុទាំងនោះ។

*iii. កំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សររបស់ កសចស បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវសក្ខីកម្មរបស់សាក្សីរូបនេះ និងត្រូវទៅតាមវិធានផ្ទៃក្នុងរបស់ អវតក*

[33] **E1/122.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៥ កញ្ញា ២០១២, ទំព័រទី ៦០-៦៥។

[34] **E1/122.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៥ កញ្ញា ២០១២, ទំព័រទី៨៧-១០០ (នៅក្នុងទំព័រទាំងនេះ មេធាវីការពារក្តីរបស់ នួន ជា ត្រូវបានដាស់តឿនដោយសារសួរសំណួរនាំមុខ និងបានដេញដោលលើពាក្យមិនចាំបាច់ ភាពស្មោះត្រង់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនសួរចូលទៅក្នុងកិច្ចនីតិវិធីនៃការស្តាប់ចម្លើយទេ)។

[35] **E1/117.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៩ សីហា ២០១២។ **E1/120.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៣ កញ្ញា ២០១២។ **E1/121.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៤ កញ្ញា ២០១២។ **E1/122.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៥ កញ្ញា ២០១២។ **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២។

[36] **E234** សំណើ, ត្រង់កថាខណ្ឌទី ១១, ១២។

២៤- ពីមុនមក អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានធ្វើការកត់សម្គាល់ថា "យោងតាមការអនុវត្តកន្លងមកតាមច្បាប់ជាតិរបស់កម្ពុជា ការស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបសួរ គឺមិនមែនជាការកត់ត្រាគ្រប់ពាក្យសម្តីគ្រប់ម៉ាត់ដោយគ្មានល្អៀងនោះទេ ប៉ុន្តែកំណត់ហេតុដែលធ្វើឡើងដោយសហចៅក្រមស៊ើបសួរទាក់ទងនឹងចម្លើយរបស់សាក្សី ភាគីដើមបណ្តឹង ឬជនជាប់ចោទ"[37]។ ដោយមិនគិតថាតើមានការពិភាក្សាបន្ថែមណាមួយកើតឡើងយ៉ាងនោះទេ កំណត់ហេតុជាលាយលក្ខណ៍អក្សរ បានសង្ខេបដោយត្រឹមត្រូវ និងច្បាស់លាស់ អំពីការដឹងឮ និងសក្ខីកម្មរបស់សាក្សី។ នង សុផង់ បានបញ្ជាក់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុនោះ ទាំងនៅពេលដែលគាត់បានធ្វើ (ដោយការចុះហត្ថលេខា និងការផ្តិតមេដៃនៅលើកំណត់ហេតុ)[38] <u>និងទាំង</u>នៅពេលដែលគាត់បានបង្ហាញខ្លួននៅក្នុងតុលាការ ដើម្បីផ្តល់សក្ខីកម្ម[39]។ ដូច្នេះ ពុំមានមូលដ្ឋានណាមួយសម្រាប់ឲ្យមេធាវីការពារក្តីធ្វើការតវ៉ាថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនោះ មិនឆ្លុះបញ្ចាំងបានត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយពីមុនៗដែលអ្នកស៊ើបអង្កេតរបស់ កសចស បានធ្វើឡើងនោះឡើយ។ ភាពមិនប្រក្រតីនៃកិច្ចដំណើរការនីតិវិធីដែលមេធាវីការពារក្តីបានចោទប្រកាន់ មិនបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាណាមួយ នៅក្នុងភ័ស្តុតាងដែលសាក្សីរូបនេះបានផ្តល់ឲ្យនោះឡើយ។

២៥- ក្នុងការព្យាយាមដើម្បីបង្កើតឡើងនូវចំណាប់អារម្មណ៍មួយនៃការប្រព្រឹត្តិខុស មេធាវីការពារក្តីមានការភាន់ច្រឡំ ដោយខំស្វែងរកសុំឲ្យយកវិធាន២៥(២)មកប្រើ សម្រាប់ការធ្វើសម្ភាសន៍សាក្សីរបស់ កសចស ដោយលើកឡើងថា នៅក្នុងកាលៈទេសៈដែលមន្ត្រីអ្នកស៊ើបអង្កេតរបស់ កសចស មិនអាចមានលទ្ធភាពថតជាខ្សែអាត់សម្លេង ឬជាវីដេអូនៃការធ្វើសម្ភាសន៍បាន នោះទាមទារឲ្យអ្នកស៊ើបអង្កេតបញ្ជាក់អំពីមូលហេតុដែលមិនអាចធ្វើដូច្នេះបានជាលាយលក្ខណ៍អក្សរ[40]។ អានភ្ជាប់គ្នាជាមួយផ្នែកផ្សេងៗទៀតនៃវិធាន២៥ ដែលក្រុមមេធាវីការពារក្តីមិនបានលើកយោង ឬមិនបានលើកយកមកពិភាក្សា វាច្បាស់ណាស់ថា វិធាន២៥(២) គឺអនុវត្តបានតែធ្វើសម្ភាសន៍ជនសង្ស័យ ឬជនត្រូវចោទតែប៉ុណ្ណោះ។

[37] **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី១១។

[38] **E3/64** កំណត់ហេតុស្តាប់ចម្លើយសាក្សី នង សុផង់, ១៨ កុម្ភៈ ២០០៩។

[39] **E1/117.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៨ សីហា ២០១២, ត្រង់ទំព័រទី៣៤។

[40] **E234** សំណើ, ត្រង់កថាខណ្ឌទី ១០, ១១ និង១៨

២៦- វិធាន២៥(១) រៀបរាប់អំពីគោលការណ៍ណែនាំសម្រាប់ការថតខ្សែអាត់ថតសម្លេង ឬជាខ្សែវីដេអូ ដែលត្រូវតែអនុវត្តតាម "នៅពេលណាដែលអាចធ្វើទៅបាន នៅពេលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត សួរយកចម្លើយពីជនសង្ស័យ ឬជនត្រូវចោទ"។ វិធាន២៥(២)នៃវិធានផ្ទៃក្នុង បានចែងបន្តពីនោះមកទៀត ដោយបានពន្យល់អំពីនីតិវិធីដែលត្រូវប្រើ នៅពេលដែលការថតខាងលើនេះមិនអាចធ្វើទៅបាន៖ "បុគ្គលម្នាក់អាចត្រូវសួរយកចម្លើយដោយមិនបាច់មានការថតសម្លេង ឬថតជារូបភាព នៅពេលណាដែលកាលៈទេសៈរារាំងចំពោះការថតសម្លេងបែបនេះ។ ក្នុងករណីនេះ មូលហេតុមិនអាចថតសម្លេងបានក្នុងពេលសួរយកចម្លើយ នឹងត្រូវបញ្ជាក់ក្នុងកំណត់ហេតុជាលាយលក្សណ៍អក្សរ..."។ បើមានការមន្ទិលសង្ស័យណាមួយថា វិធាន២៥(២)ក៏សំដៅជាពិសេសចំពោះជនសង្ស័យ ឬជនត្រូវចោទ ដែលមិនឈានទៅដល់វិធាន២៥(៤)ដែលបានចែងថា៖ "សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត *អាចជ្រើសយក* នីតិវិធីដែលមានចែងនៅក្នុងវិធាននេះ នៅពេលធ្វើការសួរយកចម្លើយ*ជនដទៃទៀត ក្រៅពីជនដែលបានរៀបរាប់ខាងលើ*..."[41]។ មានតែ "ជន" មួយចំនួនដែលបាន "លើកឡើងខាងលើនេះ" តែប៉ុណ្ណោះ គឺជនសង្ស័យ និងជនត្រូវចោទ។ និយាយតាមវិធីម្យ៉ាងទៀត បើសិនជាការប្រើពាក្យ "ជន" នៅក្នុងវិធាន២៥(២) ដែលមានន័យចង់សំដៅទៅលើជនគ្រប់រូប ជាជាងសំដៅទៅលើជនសង្ស័យ និងជនត្រូវចោទនោះ វិធាន២៥(៤) ត្រូវបកស្រាយលើសពីខ្លឹមសារពិតហើយ ពីព្រោះគ្មាន "ជនណាផ្សេងទៀត" នៅក្នុងវិធាន២៥(៤) ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងការបកស្រាយ ដោយន័យទូទៅចំពោះពាក្យ "ជន" នៅក្នុងវិធាន២៥(៤)នោះឡើយ។ អាស្រ័យហេតុនេះ ការធ្វើសម្ភាសន៍សាក្សីគឺត្រូវបានស្ថិតនៅក្រោមវិធាន២៥(៤) ដែលបញ្ជាក់យ៉ាងច្បាស់ថា កសចស "អាចជ្រើសយក" ការអនុវត្តតាមការកំណត់ដូចនៅក្នុងវិធាន២៤(១)-(៣) ប៉ុន្តែមិនត្រូវបានបង្ខំឲ្យត្រូវតែធ្វើដូច្នេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើសេចក្ដីសន្និដ្ឋានផងដែរថា វិធានផ្ទៃក្នុងរបស់ អវតក មិនបានតម្រូវថា អ្នកស៊ើបអង្កេតរបស់ កសចស ត្រូវថតបទសម្ភាសន៍សាក្សីដោយប្រើឧបករណ៍ថតសម្លេង/ថតរូបភាព ឬថតរយៈពេលពិតប្រាកដនៃការធ្វើបទសម្ភាសន៍សាក្សី និងរយៈពេលសម្រាកនៅក្នុងចន្លោះពេលនៃការធ្វើសម្ភាសន៍នោះទេ[42]។

២៧- ថ្វីត្បិតតែ អ្នកស៊ើបអង្កេតមិនត្រូវបានគេតម្រូវឲ្យធ្វើដូចនេះក៏ដោយ ការធ្វើសម្ភាសន៍ភាគច្រើនរបស់ កសចស ត្រូវបានថតសម្លេង ហើយការថតសម្លេងទាំងនោះត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង

---

[41] វិធាបន 25(4) (សង្កត់ន័យបន្ថែម).

[42] **E142/3** សេចក្ដីសម្រេចទាក់ទងនឹងការសម្ភាសន៍សាក្សី, ត្រង់កថាខណ្ឌ 6, ជើងទំព័រ 13។

ហើយមានជាស្រេចសម្រាប់មេធាវីការពារក្តី និងភាគីផ្សេងៗ យកមកពិនិត្យឡើងវិញបាន។ ដូចដែលអង្គជំនុំជម្រះបានធ្វើការកត់សម្គាល់រួចមកហើយ ការអនុវត្តរបស់ កសចស គឺវា "មិនមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តដោយចេតនា ក្នុងការរារាំងដល់ការស៊ើបសួរទេ"[43]។ នៅក្នុងករណីចំពោះមុខនេះ ក៏វាមិនស្របគ្នាផងដែរជាមួយនឹងការប៉ុនប៉ងដោយចេតនាណាមួយ ដើម្បីធ្វើជាឧបសគ្គរារាំងដល់ការស៊ើបសួរ គឺនៅត្រង់ប្រការជាក់ស្តែងដែលថា នៅក្នុងពេលថតការធ្វើសម្ភាសន៍នោះ អ្នកស៊ើបអង្កេតបានយោងដោយខ្លួនឯងទៅលើការពិភាក្សាកាលពីមុនៗ ជាមួយសាក្សី[44]។ ការចោទប្រកាន់របស់មេធាវីការពារក្តីអំពីភាពមិនសមស្របចំពោះអ្នកស៊ើបអង្កេតរបស់ កសចស ដូច្នេះ មិនមានមូលដ្ឋាន និងមិនត្រូវទេ។

២៨- បន្ថែមពីលើនេះ ក្រុមមេធាវីការពារក្តីខកខានមិនបានបំពេញគ្រប់ទៅតាមបទដ្ឋាន ដែលបានដាក់ចេញដោយអង្គជំនុំជម្រះដែលតាមរយៈនេះ នឹងធ្វើការពិចារណា"ការចោទប្រកាន់ផ្សេងៗ ស្តីពីភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់ថតសម្លេង នឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍ តែក្នុងករណីដែលនៅក្នុងឯកសារទាំងនេះត្រូវបានបញ្ជាក់ដោយលក្ខណៈពិសេសគ្រប់គ្រាន់ និងមានការជាប់ទាក់ទងទៅនឹងភាពមិនចុះសម្រុងគ្នាមួយចំនួនស្តីពីខ្លឹមសារដែលត្រូវបានចោទប្រកាន់ដែលបានបញ្ជាក់បំភ្លឺអំពីភាពពាក់ព័ន្ធនៃសវនាការជំនុំជម្រះក្តី"[45]។ មេធាវីការពារក្តីមិនបានបង្ហាញសក្ខីកម្មអំពីថាតើរបៀបជាទូទៅ ឬរបៀបដោយឡែកណាមួយគឺជាបញ្ហាដ៏មានសារៈសំខាន់ នៅក្នុងកំណត់ហេតុនៃការធ្វើសម្ភាសន៍សាក្សីជាលាយលក្ខណ៍អក្សរដែលបានធ្វើឡើងដោយ កសចស ដែរឬទេ? ហើយមេធាវីការពារក្តីមិនបានអនុវត្តទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះផងដែរដែលថា "ភាគីណាមួយដែលលើកឡើងនូវការប្រឆាំងជំទាស់ជាបន្ថែមទៀត ត្រូវតែជាអ្នកទទួលបន្ទុកក្នុងការបញ្ជាក់ឱ្យបានច្បាស់អំពីការចោទប្រកាន់ថាមានភាពមិនស្របគ្នានោះ *ហើយផ្តល់នូវការជូនដំណឹងជាមុនទាន់ពេលវេលាដល់អង្គជំនុំជម្រះ និងដល់ភាគីផ្សេងៗទៀតអំពីការចោទប្រកាន់ទាំងនេះ ព្រមទាំងឯកសារដែលពាក់ព័ន្ធនឹងការចោទប្រកាន់ទៀតផង*"[46]។ តាមពិតទៅ មេធាវីការពារក្តីមិនបានផ្តល់នូវការជូនដំណឹងឱ្យបានទាន់ពេលវេលា ឬម្យ៉ាងទៀតដល់ភាគីនានា ឬដល់អង្គជំនុំជម្រះសាលាដំបូង ថាខ្លួនមានបំណងចង់ស្វែងរកសុំធ្វើការជំទាស់ទៅនឹង នង សុផង់ ដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់អំពីភាព

---

[43] **E142/3** សេចក្តីសម្រេចទាក់ទងនឹងការសម្ភាសន៍សាក្សី, ត្រង់កថាខណ្ឌ ១៥។

[44] **E3/1739** ប្រតិចារឹកនៃកិច្ចសម្ភាសន៍ដោយផ្នែក ចុះថ្ងៃទី១៨ កុម្ភៈ ឆ្នាំ២០០៩ ទំព័រ១។

[45] **E142/3** សេចក្តីសម្រេចទាក់ទងនឹងការសម្ភាសន៍សាក្សី, ត្រង់កថាខណ្ឌ ១២។

[46] **E142/3** សេចក្តីសម្រេចទាក់ទងនឹងការសម្ភាសន៍សាក្សី, ត្រង់កថាខណ្ឌ ១២,(សង្កត់ន័យ) ។

មិនស្របគ្នា រវាងចម្លើយរបស់គាត់កាលពីមុន និងខ្សែអាត់ថតសម្លេងនៃការធ្វើសម្ភាសន៍គាត់។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានទាមទារជាលើកទីមួយ នៅពេលដែលពួកគេកំពុងសួរដេញដោលសាក្សី និង *បន្ទាប់ពី* សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានទៅលើការសួរដេញដោលរបស់គេ លើសាក្សីរូបនេះ។

## ខ. ក្រុមមេធាវីការពារក្តីមិនបានធ្វើសំណើរបស់ខ្លួនដោយសុចចិត្តឡើយ

២៩- ការបញ្ជាក់អំពីថា ក្រុមមេធាវីការពារក្តីមិនបានធ្វើសំណើរដោយសុទ្ធចិត្តនោះ ជាអកុសល មិនត្រូវបានបញ្ចប់ដោយសារការបកស្រាយខុសនៅក្នុងសំណើរបស់ខ្លួនដូចដែលបានធ្វើការកត់សម្គាល់រួចមកហើយនោះឡើយ។ ក្នុងអំឡុងពេលស្តាប់សក្ខីកម្ម នង សុផង់ មេធាវីការពារក្តីបានបញ្ជាក់ច្បាស់ប្រាប់តុលាការថា មេធាវីការពារក្តីបាន “យល់” និង “បានវាយតម្លៃខ្ពស់” ចំពោះការប្រកាសរបស់អង្គជំនុំជម្រះស្តីពី “កាលៈទេសៈពិសេសនានា” ពួកគេត្រូវតែបង្ហាញ ដើម្បីធ្វើយុត្តិកម្មការសួរដេញដោលអំពីសកម្មភាពក្នុងដំណាក់កាលនៃការស៊ើបសួរ ហើយដែលបានសន្យាថាពួកគេនឹង “ខិតខំខ្នះខ្នែងក្នុងការធ្វើរឿងនេះ...ព្រោះឥឡូវនេះពួកខ្លួនបានយល់អំពីជំហររបស់តុលាការហើយ”[47]។ ទោះបីយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តីមិនបានធ្វើការបង្ហាញដូចនេះនៅទីនេះឡើយ។

៣០- ជាងនេះទៅទៀត ទោះបីជាកំពុងត្រូវបានជូនដំណឹងដោយលោកស្រីចៅក្រម Cartwright ថា ទាក់ទងទៅនឹងដំណាក់កាលនៃការស៊ើបសួរ “សំណើណាមួយ អំពីភាពមិនសមស្រប គឺ ការពិតពួកគេគឺជាអ្នកខុសត្រង់ខ្លួនឯងតែម្តង”ទោះជាបានដឹងថា សេចក្តីណែនាំ[48] ហើយថ្វីបើត្រូវបាននិយាយប្រាប់ដោយលោកចៅក្រម Lavergne នៅក្នុងពេលសួរដេញដោល នង សុផង់ ថា “បញ្ហាទាំងឡាយដែលត្រូវបានលើកឡើងនៅក្នុងពេលសវនាការគួរតែត្រូវបានលើកឡើងជាចំហរ ដោយក្នុងនោះមិនមានការចោទប្រកាន់ដែលថាការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតមានភាពមិនសុច្ចរិត ឬការលួចបន្លំ” នោះឡើយ និងថា “នៅដំណាក់កាលនេះនៃដំណើរការនីតិវិធីសវនាការ” ការចោទប្រកាន់នានាបែបនេះគឺវាមិនសមស្របឡើយ”[49]។ នៅក្នុងសំណើក្រុមមេធាវីការពារក្តីបានសំដៅទៅលើថា វិធានការ

---

[47] **E1/123.1** ប្រតិចារឹកនៃកិច្ចសម្ភាសន៍ដោយផ្នែក ចុះថ្ងៃទី៦ កញ្ញា ឆ្នាំ២០១២ ទំព័រ៤៤។

[48] **E1/123.1** ប្រតិចារឹកនៃកិច្ចសម្ភាសន៍ដោយផ្នែក ចុះថ្ងៃទី៦ កញ្ញា ឆ្នាំ២០១២ ទំព័រ៤៥។

[49] **E1/122.1** ប្រតិចារឹកនៃកិច្ចសម្ភាសន៍ដោយផ្នែក ចុះថ្ងៃទី៥ កញ្ញា ឆ្នាំ២០១២ ទំព័រ៩៥។

ទាំងនេះរបស់ កសចស ថាគឺជា "ការលាក់លៀម"[50] គឺជា "ល្បិចល្បែងដើម្បីយកឈ្នះនៅក្នុងការស៊ើបសួរ"[51], គឺជា "ការលាក់បាំង"[52], "ដែលលាក់បាំងនូវការដែលបានកើតមានចំពោះការធ្វើសម្ភាសន៍ពីមុនៗដែលមិនបានថតសម្លេងឬថតជាវីដេអូ/ធ្វើកំណត់ហេតុ "[53],គឺថាការរៀបចំជាមុនយ៉ាងហោចណាស់ក៏ ការធ្វើសម្ភាសន៍ដែលបានថតសម្លេង ឬថតជាវីដេអូ/ធ្វើកំណត់ហេតុ មួយដែរ[54], គឺជា "ការពាក់របាំងមុខដើម្បីក្លែង"[55], ហើយដែល បង្កប់ន័យថា ពួកគេអាច "ចាត់ចែងដោយឧបាយកល" ទៅលើសាក្សី[56]។

៣១- ក្រុមមេធាវីការពារក្តីក៏បាន "រួមបញ្ចូលក្នុងនោះផងដែរដោយយោង"[57]ទៅលើការដាក់សារណារបស់ខ្លួនកាលពីមុនៗមក ហើយបានព្រើពាក្យពេចន៍ចំពោះវិធានការណ៍របស់ កសចស ថាគឺជា "ល្បិចដើម្បីដោះខ្លួន : កិច្ចស៊ើបសួរដែលបានរៀបចំឡើងមួយ"[58], "ការនាំឲ្យយល់ខុស ដោយ ចេតន"[59], "ដែលបានរៀបចំជាមុន និងដែលប្រឌិតដើម្បីបោកប្រាស់"[60], ដែលបានធ្វើឡើងដោយមានការលាក់លៀមនូវវគ្គសំនួរ និងចម្លើយដោយមិនបានថតសំឡេង/ថតវីដេអូ (ធ្វើកំណត់ហេតុ) អ្នកស៊ើបអង្កេតរបស់ កសចស បានរៀបចំគម្រោងដើម្បីគ្រប់គ្រង ហើយបើសិនជាចាំបាច់បង្កើត,...សក្ខីកម្មតែម្តង"[61],តាមរយៈការបង្កើតឡើងនូវ "វគ្គអនុវត្តជាក់ស្តែងមួយ ដែលបានរៀបចំឡើងដើម្បីប្រើប្រាស់ឥទ្ធិពល/ការចាត់ចែងដោយកលល្បិច ទៅលើចម្លើយដែលបានធ្វើកំណត់ហេតុ/ដែលបានថតសម្លេង

---

[50]**E234** សំណើសុំ កថាខណ្ឌ៦

[51] **E234** សំណើសុំ កថាខណ្ឌ១០

[52] **E234** សំណើសុំ កថាខណ្ឌ១៤.

[53] **E234** សំណើសុំ កថាខណ្ឌ១៩

[54] **E234** សំណើសុំ កថាខណ្ឌ១៩

[55] **E234 E234** សំណើសុំ កថាខណ្ឌ១៤.

[56] **E234** សំណើសុំ កថាខណ្ឌ៦

[57] **E234** សំណើសុំ ទំព័រ១

[58] **E221** សំណើសុំរបស់ អៀង សារី សុំឲ្យបើកសវនាការស្តាប់សក្ខីកម្មពីអ្នកបកប្រែទាក់ទងនឹងកិច្ចសម្ភាសន៍លើកទី២ របស់ កសចស ចំពោះ សាក្សី ភី ភួន ដែលកិច្ចសម្ភាសន៍នោះ មានភាពមិនប្រក្រតីកើតឡើងមានន័យថា បន្ត ចុះថ្ងៃទី២៣ សីហា ឆ្នាំ២០១២ ទំព័រ១ សូមមើលដូចខាងលើដែរ ត្រង់កថាខណ្ឌ១៥។ **E224** សំណើសុំរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះស្វែងរកការពន្យល់បន្ថែមពី កសចស អំពីអត្ថភាពកំណត់ហេតុណាមួយដែលទាក់ទងនឹងការសួរចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ តុលា ឆ្នាំ២០០៨ ថ្ងៃទី២៩ សីហា ឆ្នាំ២០១២ (ដែលចាប់ពីពេលនេះហៅថា សំណើរបស់ អឿន តាន) ត្រង់កថាខណ្ឌ៦។

[59] **E224** សំណើរបស់ អឿន តាន ត្រង់កថាខណ្ឌ៦

[60] **E224** សំណើរបស់ អឿន តាន ត្រង់កថាខណ្ឌ៦

[61] **E224** សំណើរបស់ អឿន តាន ត្រង់កថាខណ្ឌ៧

និងវីដេអូ [របស់សាក្សី]"[62] , "ដោយបានដឹងថាកំណត់ហេតុលាយលក្ខណ៍អក្សរនៃការធ្វើសម្ភាសន៍សាក្សី"មុខជានឹងត្រូវបានជឿទុកចិត្តដោយអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ជាពិសេស ចាប់តាំងពីសាក្សីបានចុះហត្ថលេខានៅលើនោះ ដោយពុំមានការជំទាស់ ហើយមន្ត្រីអ្នកស៊ើបអង្កេតរបស់ កសចស បានបង្ហាញនូវកំណត់ហេតុដែលមិនពេញលេញ មិនត្រឹមត្រូវ និងដែលនាំឲ្យមានការយល់ខុស[63], ដែលជាប់ជំពាក់នៅក្នុង "ការខកខានមួយក្នុងការទទួលស្គាល់ចំពោះអត្ថិភាពនៃវគ្គសំណួរ និងចម្លើយមួយដែលមិនបានថតសម្លេងឬថតវីដេអូ/ធ្វើកំណត់ហេតុ"[64] ហើយដែលបានថ្លែងថា "មន្ត្រីអ្នកស៊ើបអង្កេតរបស់ កសចស មានចេតនាផ្តល់នូវការពិតត្រឹមតែពាក់កណ្តាលជូនដល់អង្គជំនុំជម្រះសាលាដំបូង និងភាគី"[65]។ ក្រុមមេធាវីការពារក្តីក៏បានលើកយោងសាជាថ្មីផងដែរ ទៅលើពត៌មានដែលពួកគេបានប្រមូលបានសួរចម្លើយអ្នកបកប្រែជាលក្ខណៈឯកជនទាក់ទងនឹងបញ្ហាដែលពួកគេមានបំណងកោះអញ្ជើញអ្នកប្រែក្នុងឋានៈជាសាក្សី ដើម្បីផ្តល់សក្ខីកម្មលើបញ្ហាទាក់ទងនឹងទង្វើ ដែលសហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ច្បាស់ណាស់ថាមានការរំលោភលើវិធាន៣៥(១)(ឃ) ដែលហាមមិនឲ្យជ្រៀតជ្រែកចំពោះសាក្សីមានសក្តានុពលនេះ[66]។

៣២- ទាំងអស់នេះបញ្ជាក់ថា សំណើសុំនេះ មិនមែនធ្វើឡើងដោយសុទ្ធចិត្តក្នុងការដាក់សារណាដើម្បីស្វែងរកពត៌មានដែលអាចជួយជម្រុញតាមផ្លូវច្បាប់ក្នុងការស្វែងរកការពិតនោះទេ។ ជាងនេះទៀត ទង្វើទាំងនេះគឺជាល្បិចបង្វែងខុសពីការពិតទាំងស្រុងដែលត្រូវបានគេរៀបចំឡើង ដើម្បីបង្កើតអោយមានការយល់ខុសអំពីភាពចំរូងចម្រាស់នៃនីតិវិធីនៅក្នុងដំណាក់កាលនៃការកសាងភ័ស្តុតាងប្រឆាំងជនជាប់ចោទតែប៉ុណ្ណោះ។

[62] **E224** សំណើរបស់ អៀង តាន ត្រង់កថាខណ្ឌ៨

[63] **E224** សំណើរបស់ អៀង តាន ត្រង់កថាខណ្ឌ៩

[64] **E224** សំណើរបស់ អៀង តាន ត្រង់កថាខណ្ឌ១៤

[65] **E224** សំណើរបស់ អៀង តាន ត្រង់កថាខណ្ឌ១៨

[66] **E234** សំណើ ត្រង់កថាខណ្ឌ១៩។ **E221/1** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី សុំឲ្យបើកសវនាការស្តាប់សក្ខីកម្មពីអ្នកបកប្រែទាក់ទងនឹងកិច្ចសម្ភាសន៍លើកទី២ របស់ កសចស ទៅលើសាក្សី ភី ភួន ចុះថ្ងៃទី៤ កញ្ញា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ២០-២២។

## III. សេចក្តីសន្និដ្ឋាន

៣៣- មិនមានភាពមិនចុះសម្រុងគ្នា រវាងក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញានោះទេ ថាអង្គជំនុំជម្រះសាលាដំបូងមានអំណាចក្នុងការចាត់វិធានការបើកកិច្ចស៊ើបសួរអនុលោមតាមវិធាន៩៣នៃវិធានផ្ទៃក្នុង។ ករណីបើសិនជាមានការមិនចុះសម្រុងគ្នាលើបញ្ហាសំខាន់ណាមួយអំពីថា តើអង្គជំនុំជម្រះគួរអនុវត្តសិទ្ធិដោយផ្អែកលើការចោទប្រកាន់ដែលគ្មានមូលដ្ឋាន ដែលមានលក្ខណៈខុសគ្នាស្រឡះទៅកំណត់ហេតុនោះ (ដូចដែលក្រុមមេធាវីការពារក្តីបានលើកឡើង ដែរ ឬទេ?) ឬមួយក៏ថាតើអំណាចនោះគួរ ឬតែត្រូវបានអនុវត្ត ដោយមានការពិចារណាយ៉ាងហ្មត់ចត់ និងស្ថិតនៅក្រោមកាលៈទេសៈកម្រិតដែលមិនមានវត្តមានទាល់តែសោះនៅទីនេះ។

៣៤- ហេតុផលដូចបានរៀបរាប់នៅក្នុងសេចក្តីផ្តើមនៃសំណើរនេះ សហព្រះរាជអាជ្ញាមិនមានការជំទាស់ទេចំពោះសំណើរបស់ក្រុមមេធាវីការពារក្តីដែលថា "បើសិនជាពិតមានអត្ថិភាពនៃកំណត់ហេតុក្នុងការធ្វើសម្ភាសន៍កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ មែននោះ" ត្រូវដាក់បញ្ចូលវាទៅក្នុងសំណុំរឿង ដើម្បីឱ្យភាគីទាំងពិនិត្យមើលឡើងវិញ និងប្រើប្រាស់"[67] ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែបដិសេធចោលនូវផ្នែកផ្សេងទៀតទាំងអស់នៃសំណើនេះដោយសារតែគ្មានអង្គសេចក្តី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew Cayley<br>សហព្រះរាជអាជ្ញា | | |

[67] **E234** សំណើ ត្រង់ទំព័រ១៥